00192140

E2/L/14

# នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

("អ.វ.ត.ក")

សំណុំរឿងលេខ: 002/19-09-2007-ECCC-OCIJ (PTC03)

ឈ្មោះសំណុំរឿង: អៀង សារី

ដាក់ជូនទៅ: អង្គបុរេជំនុំជម្រះ

កាលបរិច្ឆេទដាក់ជូន: ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨

ភាគីដាក់: លោក Mahdev MOHAN និងលោកស្រី Vinita Ramani MOHAN

ភាសា: អង់គ្លេស

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 26 / 05 / 2008
ម៉ោង (Time/Heure): 09h00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

---

## សារណាសាធារណៈ: ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 26 / 05 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

Original EN: 00164285-00164303

C22/I/14

## តារាងនៃមាតិកា


I. ផលប្រយោជន៍នៃសាធារណៈ

II. សេចក្តីសង្ខេបនៃអំណះអំណាង

III. បញ្ហាដែលលើកឡើង

IV. អំណះអំណាង

A. ការជំនុំជម្រះ និងសាលក្រមនៃតុលាការបដិវត្តប្រជាជនពុំមានទំនាក់ទំនងជាមួយកិច្ចដំណើរការនីតិវិធីនៃ អ.វ.ត.ក ចំពោះភាគីប្តឹងឧទ្ធរណ៍ទេ

B. ការិយាល័យសហចៅក្រមស៊ើបអង្កេត មានសិទ្ធិឃុំខ្លួនភាគប្តឹងឧទ្ធរណ៍បណ្តោះអាសន្ន ទោះបីមានការលើកលែងទោសក៏ដោយ

C. បទដ្ឋាននៃការពិនិត្យឡើងវិញរបស់តុលាការដែលតម្រូវឱ្យបដិសេធចោលដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងការដោះលែងឱ្យនៅស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺមិនងាយបំពេញតាមបាននោះឡើយ។

1. ការបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ឬការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ គឺជាសេចក្តីសម្រេចដោយឆន្ទានុសិទ្ធិ ដែលមានតែការិយាល័យសហចៅក្រមស៊ើបអង្កេតម្នាក់ឯងប៉ុណ្ណោះអាចធ្វើបាន និងក្នុងករណីចាំបាច់ អាចពិនិត្យឡើងវិញបាន។

2. ការខកខានមិនបានបញ្ចូលអង្គហេតុទៅក្នុងសំអាងហេតុដែលគាំទ្រដល់ដីកាសម្រេចឲ្យឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត គឺមិនមែនជាកំហុសឆ្គងដែលអាចប្តឹងឧទ្ធរណ៍បានឡើយ។

3. ភាគីបណ្តឹងឧទ្ធរណ៍ទទួលបន្ទុកក្នុងការបង្ហាញនូវហេតុផលនៃការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ជំនួសឱ្យដីកាសម្រេចឃុំខ្លួននៃការិយាល័យសហចៅក្រមស៊ើបអង្កេត

4. ការជំនុំជម្រះក្តីលើភាគីបណ្តឹងឧទ្ធរណ៍ខិតជិតមកដល់

V. **សន្និដ្ឋាន**

I. **ផលប្រយោជន៍នៃសារណាសាធារណៈ**

1. យើងខ្ញុំសូមនិយាយដល់សេចក្តីជូនដំណឹងជាសាធារណៈរបស់ប្រធាននៃអង្គបុរេជំនុំជម្រះ នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៨ ("សេចក្តីជូនដំណឹងសាធារណៈ")ដែលអញ្ជើញឱ្យដាក់ *សារណាសាធារណៈ* ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍ ដែលធ្វើឡើងដោយលោក អៀងសារី ("សារណានៃបណ្តឹងឧទ្ធរណ៍") ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត("OCIJ") ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ ("ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន")។
2. នេះគឺជាសារណាសាធារណៈមួយដែលរៀបចំឡើងដោយរួមគ្នាដោយ លោក Mahdev MOHAN និង លោកស្រី Vinita Ramani MOHAN។ លោក Mahdev Mohan, *ASIArb* គឺជាសាស្ត្រាចារ្យច្បាប់មួយរូប នៅសាកលវិទ្យាល័យគ្រប់គ្រងនៃប្រទេសសឹង្ហបូរី និងនិស្សិត Fulbright ។ គាត់គឺជាអតីតមេធាវីធ្វើសកម្មភាពមិនគិតផលកម្រៃ(២០០៧)នៃមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយមានគោលដៅតាមឃ្លាំមើលការប្រតិបត្តិន៍សិទ្ធិមនុស្ស យុត្តិធម៌ និងការបង្រួបបង្រួមជាតិនៅកម្ពុជា។ គាត់ក៏ជាអតីតដៃគូ (២០០៧)នៃគម្រោងផ្តួចផ្តើមយុត្តិធម៌អន្តរជាតិអាស៊ីជាគម្រោងសហការ រវាងមជ្ឈមណ្ឌលសិក្សា ពីឧក្រិដ្ឋកម្មសង្គ្រាមនៅសាកលវិទ្យាល័យកាលីហ្វូញ៉ា (Berkeley) និងEast-West Centerនៅសាកលវិទ្យាល័យហាវៃបង្កើតឡើងដើម្បីជំរុញឱ្យមានគំនិតផ្តួចផ្តើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពទូទាំងតំបន់អាស៊ីប៉ាស៊ីភិច។ លោក Mohan គឺជាមេធាវីនៃតុលាការជាន់ខ្ពស់របស់ប្រទេសសឹង្ហបូរី និងជាអតីតព្រះរាជអាជ្ញាយោធា ដែលបានបំរើការជាមួយក្រសួងការពារជាតិ(សឹង្ហបូរី)។
3. លោកស្រីVinita Ramani Mohan គឺជាជំនួយការផ្នែកស្រាវជ្រាវ ជាមួយសាលា Rajaratnamនៃការសិក្សាអន្តរជាតិ(សឹង្ហបូរី) និងសាខានៃវិទ្យាស្ថានស្រាវជ្រាវអាស៊ី

(សឹង្ហបូរី)។ លោកស្រីគឺជាAsia Fellowជាមួយមូលនិធិអាហារូបករណ៍អាស៊ី(ASF)ពីខែកក្កដា ឆ្នាំ២០០៧ ដល់ខែមករា ឆ្នាំ២០០៨។ ក្នុងអំឡុងពេលនេះ លោកស្រីបានដឹកនាំការស្រាវជ្រាវស្តីពីស្មារតីសង្គមនៅកម្ពុជា និងតួនាទីអង្គការសង្គមស៊ីវិលនានាក្នុងតុលាការខ្មែរក្រហម។ ដាច់ចេញពីការស្ម័គ្រចិត្តបំពេញការងារជាមួយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម និងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកស្រីMohanបានដឹកនាំការសម្ភាស៍ជាច្រើនជាមួយអ្នកនៅសល់ពីស្លាប់ពីរបបខ្មែរក្រហមទាំងចាស់ទាំងក្មេង អំពីការការចងចាំ ឬចំណេះដឹងរបស់ខ្លួនសម័យខ្មែរក្រហម ព្រមទាំងសេចក្តីរំពឹង និងចំណាប់អារម្មណ៍របស់ពួកគេក្នុងការជំនុំជម្រះនាពេលខាងមុខ។ លោកស្រីគឺជាអតីតអ្នកកាសែតនៃSignapore's daily newspaper TODAYផងដែរ ដែលលោកស្រីមានការិយាល័យទាំងនៅក្នុងស្រុកនិងក្រៅប្រទេសផងដែរ។

4. យើងខ្ញុំសូមបញ្ជាក់ថា សារណានេះគឺជាទស្សនៈអព្យាក្រិត្យមួយលើចំនុចផ្សេងៗនៃច្បាប់ដែលបានលើកឡើងក្នុងដីកាសម្រេចឃុំខ្លួន និងសារណាបណ្តឹងឧទ្ធរណ៍។ វិសាលភាពនៃសារណានេះមានកម្រិតក្នុងការជួយអង្គជំនុំជម្រះក្នុងការសម្រេចលើចំនុចទាំងឡាយដោយខ្លួនឯង និងមិនធ្វើឱ្យប៉ះពាល់ដល់ភាពគ្មាន ទោស ឬពិរុទ្ធភាពនៃភាគីបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងបទឧក្រិដ្ឋទាំងឡាយដែលគាត់បានជាប់ចោទបច្ចុប្បន្ននេះទេ។ ការពិនិត្យមើលរបស់ខ្ញុំផ្អែកលើយុត្តិសាស្ត្រ និងការប្រតិបត្តិរបស់តុលាការ[១]ឧក្រិដ្ឋកម្មអន្តរជាតិ និងកូនកាត់ តុលាការឧក្រិដ្ឋកម្មអន្តរជាតិ(ICC) អត្ថបទរបស់អ្នកប្រាជ្ញ និងអង្គការសង្គមស៊ីវិលទាក់ទងនឹងការពិនិត្យជាក់ស្តែងលើលក្ខណៈវិនិច្ឆ័យក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។

5. យើងខ្ញុំសូមទទួលស្គាល់ថា បន្ថែមទៅលើការអនុវត្តន៍ច្បាប់កម្ពុជា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក (រួមទាំងការធ្វើវិសោធនកម្ម)ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥(ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក) និងវិធានផ្ទៃក្នុងរបស់អ.វ.ត.ក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៧ អ.វ.ត.កត្រូវអនុវត្តនូវយុត្តាធិការរបស់ខ្លួន *"យោងតាមបទដ្ឋានអន្តរជាតិនៃយុត្តិធម៌ ភាពត្រឹមត្រូវ និងកិច្ចដំណើរការត្រឹមត្រូវនៃច្បាប់ ដូចមានចែងក្នុងមាត្រា១៤និង១៥នៃអនុ*

---

[១] គឺ តុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់អតីតយូហ្គូស្លាវី("ICTY") តុលាការឧក្រិដ្ឋកម្មអន្តរជាតិសំរាប់រ៉្វាន់ដា("ICTR") និង តុលាការពិសេសសំរាប់ប្រទេសសេរ៉ាលេអូន("SSCL")។

*សញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ("ICCPR")* " ក្រោមមាត្រា១២នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣។

## II. សេចក្តីសង្ខេបនៃអំណះអំណាង

6. អ.វ.ត.ក នឹងពិចារណាតែទៅលើឧក្រិដ្ឋកម្មទាំងឡាយគួរឱ្យស្អប់ខ្ពើមបំផុត ដែលមនុស្សជាតិបានដឹងប៉ុណ្ណោះ ពោលគឺ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមដ៏ធ្ងន់ធ្ងរបំផុត។ នៅក្នុងដំណាក់ពិសេសនេះ តាមពិត អ.វ.ត.ក តុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងតុលាការកូនកាត់ដទៃទៀត ដែលមានយុត្តាធិការជំនុំជម្រះជនទាំងឡាយ ដែលជាប់ចោទពីការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ មានការទទួលខុសត្រូវក្នុងការលាតត្រដាង និងថ្លឹងថ្លែងនូវការពិចារណាទាំងឡាយ នៅពេលខ្លួនសម្រេចថាតើចេញដីកា ឬមិនចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទ ឬត្រូវដោះលែងជនត្រូវចោទ ដូចជាភាគីបណ្តឹងឧទ្ធរណ៍។

7. ទស្សនៈរបស់យើងខ្ញុំ លាតត្រដាងនូវអង្គច្បាប់ចំនួនបីដាច់ដោយឡែកពីគ្នា ដែលយើងខ្ញុំសង្ឃឹមថា អាចបង្ហាញផ្លូវអង្គចៅក្រមជាទីគោរពក្នុងការធ្វើសេចក្តីសម្រេចរបស់ខ្លួន។ អង្គច្បាប់ទីមួយ៖ ឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការសម្រេចថាតើវាជាការចាំបាច់ ដែលត្រូវឃុំខ្លួនភាគីបណ្តឹងឧទ្ធរណ៍បណ្តោះអាសន្ន និងថាតើឆន្ទានុសិទ្ធិនោះគឺជាអង្គច្បាប់មួយ ដែលត្រូវអនុវត្តសមស្រប ឬយ៉ាងណា។ វាហាក់ដូចជាច្បាស់ណាស់ថា សេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការឃុំខ្លួនភាគីបណ្តឹងឧទ្ធរណ៍បណ្តោះអាសន្នធ្វើឡើងក្នុងផលប្រយោជន៍សាធារណៈនោះ វាឋិតក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិរបស់ខ្លួន។ ជាមួយគ្នានេះផងដែរ ដោយសារតែបទដ្ឋានតឹងរឹងសម្រាប់ការពិនិត្យឡើងវិញ ដែលគេបានកំណត់រួចមកហើយនៅក្នុងសាលាក្តីអន្តរជាតិផ្សេងៗទៀតនោះ វាគឺជាចំណុចមួយដែលត្រូវចោទសួរថាតើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអាចត្រូវគេយកមកធ្វើជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍បានដែរឬយ៉ាងណា នេះបើគេពិចារណាទៅលើរាល់កាលៈទេសៈទាំងអស់ រួមទាំងការអនុវត្តន៍ជាក់ស្តែងនៅក្នុងប្រទេសកម្ពុជា ដូចមានរៀបរាប់ត្រួសៗក្នុងខថាខ័ណ្ឌ 16 -19 សេចក្តីសម្រេចឃុំខ្លួននោះ

ស្រាប់។ ក្នុងពេលអនាគត ការិយាល័យសហចៅក្រមស៊ើបអង្កេតគួរតែផ្តល់យុត្តិកម្មសមស្របអំពីមូលហេតុដែលត្រូវឃុំខ្លួន ឬត្រូវដោះលែងជនត្រូវចោទបណ្តោះអាសន្ន ដើម្បីជាសរាងកុំឱ្យគេជំទាស់នឹងសេចក្តីសម្រេចរបស់ខ្លួន ដោយផ្អែកលើការប៉ាន់ស្មាន និងគ្មានសំអាង។ ការិយាល័យសហចៅក្រមស៊ើបអង្កេត គួរប្រើ ប្រាស់ដោយប្រសិទ្ធិភាព នូវការសិក្សា និងរបាយការណ៍ទាំងឡាយ ដែលធ្វើឡើងដោយអង្គការសង្គមស៊ីវិលក្នុងស្រុក និងអន្តរជាតិ និងអ្នកនិពន្ធទាំងឡាយ ដែលក្តាប់បានយ៉ាងទូលំទូលាយនូវទស្សនៈ ការយល់ដឹងជាសាធារណៈ និងទំនុកចិត្ត ទាក់ទងនឹងអ.វ.ត.ក ដោយ ពិចារណាទៅការចាប់ខ្លួនការឃុំខ្លួនបណ្តោះអាសន្ន និងការជំនុំជម្រះជនត្រូវចោទដូចជាភាគីបណ្តឹងឧទ្ធរណ៍។

8. អង្គច្បាប់ទីពីរ៖ ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនចាំបាច់សួរថាតើកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នប្រឆាំងនឹងភាគីបណ្តឹងឧទ្ធរណ៍ រំលោភដល់សាលក្រម និងការកាត់ទោសប្រហារជីវិត ដែលតុលាការបដិវត្តប្រជាជន បានរៀបចំការជំនុំជម្រះឡើងក្នុងឆ្នាំ១៩៧៩ នោះទេ។ យើងខ្ញុំយល់ឃើញថា នេះមិនមែនជាបញ្ហាមួយទេ៖ ព្រះរាជក្រិត្យលើកលែងទោសភាគីបណ្តឹងឧទ្ធរណ៍ឆ្នាំ១៩៩៦ទាក់ទងនឹងការដាក់ខ្មែរក្រហមជាឧក្រិដ្ឋជន បានដាក់សាលក្រមរបស់តុលាការបដិវត្តប្រជាជនជាមោឃៈ។ ទោះបីការជំនុំជម្រះនិងសាលក្រមរបស់តុលាការបដិវត្តប្រជាជន ត្រូវគេបកស្រាយថា ជាឧបសគ្គផ្នែកច្បាប់មួយដល់ការចោទប្រកាន់របស់អ.វ.ត.ក តាមរយៈការផ្តល់លទ្ធភាពគោលការណ៍ជំនុំជម្រះពីរដងចំពោះបទល្មើសតែមួយក៏ដោយ ក៏ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនបានធ្វើការពន្យល់គ្រប់គ្រាន់អំពីរបៀប ដែលកិច្ចដំណើរការនីតិវិធីកន្លងទៅទាំងនោះ ធ្លាក់ក្រោមការលើកលែងចំពោះគោលការណ៍នេះ ហើយក៏ពុំបានពន្យល់អំពីរបៀបនៃកិច្ចដំណើរការនីតិវិធីបច្ចុប្បន្នរបស់អ.វ.ត.ក មានលក្ខណៈខុសគ្នាពីការជំនុំជម្រះនិងសាលក្រមរបស់តុលាការបដិវត្តប្រជាជន ទាំងអង្គហេតុនិងអង្គច្បាប់ ដាច់ចេញពីចរិតលក្ខណៈច្បាប់អន្តរជាតិដែរ។

9. អង្គច្បាប់ទីបី៖ តាមការជាក់ស្តែង ការលើកលែងទោស មិនបញ្ឈប់នូវអំណាចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នទេ ទោះបីអង្គចៅក្រមផ្សេងទៀតរបស់អ.វ.ត.ក មិនធ្វើការសម្រេចអ្វីផ្សេងក្រៅពីនេះក៏

ដោយ។ វាជាអកុសល ដែលច្បាប់មិនកម្រិត ឬទុកជាមោឃៈនូវអនុភាពនៃការលើកលែងទោស។ ប៉ុន្តែយើងខ្ញុំ ឯកភាពជាមួយនឹងការបកស្រាយរបស់ការិយាល័យសហចៅស៊ើបអង្កេត ដែលថា ច្បាប់ស្តីពីការបង្កើតអ.វ.ត.កផ្តល់អំណាចឱ្យធ្វើដូច្នោះ។ យើងខ្ញុំសូមបន្ថែមថា ការកម្រិត ឬការទុកជាមោឃៈនូវវិសាលភាពនៃការលើកលែងទោសដែលមានពីមុនមកគឺវាស្របនឹងយុត្តិសាស្ត្រ ការអនុវត្តន៍ និងស្របទៅនឹងច្បាប់ទម្លាប់អន្តរជាតិ ទាក់ទងនឹងការលើកលែងទោជាទូទៅដែលទទួលបានកិច្ចការពារពីជាតិដល់អ្នកប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិ។

## III. បញ្ហាដែលបានលើកឡើង

10. ជាសង្ខេប បញ្ហាចំនួនបីលើកឡើងជូនអង្គចៅក្រមជាទីគោរពសំរាប់ពិចារណាលើបណ្តឹងឧទ្ធរណ៍ គឺៈ

a) ថាតើការិយាល័យសហចៅក្រមស៊ើបអង្កេតមានសិទ្ធិចេញដីកាឃុំខ្លួនដែរ ឬអត់ បើតុលាការបដិវត្តប្រជាជនបានជំនុំជម្រះ និងបានចេញសាលក្រមក្នុងឆ្នាំ១៩៧៩ ម្តងរួចទៅហើយនោះ។

b) ថាតើការិយាល័យសហចៅក្រមស៊ើបអង្កេតមានសិទ្ធិចេញដីកាឃុំខ្លួនដែរឬអត់ បើជននោះត្រូវទទួលបានការលើកលែងទោសកាលពីឆ្នាំ១៩៩៦ រួចទៅហើយនោះ។

c) ថាតើគួរពិនិត្យនូវការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាសម្រេចឃុំខ្លួនដែរឬយ៉ាងណា។

## IV. អំណះអំណាង

### A. ការជំនុំជម្រះ និងសាលក្រមនៃតុលាការបដិវត្តប្រជាជនពុំមានទំនាក់ទំនងជាមួយកិច្ចដំណើរការនីតិវិធីអ.វ.ត.ក ចំពោះភាគីបណ្តឹងឧទ្ធរណ៍ទេ

11. ក្រោមគោលការណ៍ *គ្មានការកាត់ទោសពីរដងចំពោះបទល្មើសតែមួយ* តុលាការមួយមិនអាចផ្តួចផ្តើមបង្កើតកិច្ចដំណើរការនីតិវិធី ប្រឆាំងនឹងបុគ្គលម្នាក់ចំពោះបទល្មើសមួយដែលបានក្លាយជាកម្មវត្ថុនៃកិច្ចដំណើរនីតិវិធីព្រហ្មទណ្ឌរួចហើយ នៅចំពោះមុខតុលាការជាតិ ឬអន្តរជាតិមួយ និងប្រឆាំងនឹងបុគ្គលម្នាក់ ដែលត្រូវបានកាត់ឱ្យជាប់ទោស ឬត្រូវ

បានដោះលែងរួចហើយនោះទេ។ គោលការណ៍នេះ ត្រូវគេរៀបចំជាប្រព័ន្ធច្បាប់ក្នុងលក្ខន្តិកៈទាំងឡាយនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ព្រមទាំងបានធ្វើសច្ចាប័ណ្ណជាឯកសារច្បាប់អន្តរជាតិយ៉ាងទូលំទូលាយ និង បានវិវត្តន៍ទៅជាវិធាននៃទម្លាប់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិទាក់ទងនឹងឧក្រិដ្ឋកម្មអន្តរជាតិសាហាវយង់ឃ្នង[២]។ *គោលការណ៍កាត់ទោសពីរដងចំពោះបទល្មើសតែមួយ* មិនយកមកអនុវត្តទេនៅពេលឋិតក្នុងការជំនុំជម្រះលើកទីមួយ[៣]៖

a) បុគ្គលដែលត្រូវបានចោទប្រកាន់ និងដាក់ទោសទណ្ឌចំពោះអង្គហេតុ ឬការប្រព្រឹត្តដូចគ្នា ប៉ុន្តែបទឧក្រិដ្ឋមានចរិតជាបទឧក្រិដ្ឋធម្មតា (ឧទាហរណ៍ ឃាតកម្ម) មិនមែនជាឧក្រិដ្ឋកម្មអន្តរជាតិទេ (ឧទាហរណ៍ អំពើប្រល័យពូជសាសន៍) មានចេតនាចៀសវាងស្លាកស្នាមទុយស៍ និងការជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិ ឬ

b) ការកាត់ទោស ឬតុលាការមិនបានប្រព្រឹត្តទៅដោយវិរិយភាពតាមបទដ្ឋានអន្តរជាតិតម្រូវនោះទេ ឬ

c) តុលាការមិនបានអនុវត្តតាមកិច្ចការពារជាមូលដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ទេ ឬមិនបានបំពេញការងារដោយឯករាជ ឬអនាគតិ ឬ

d) តុលាការបានដឹកនាំការជំនុំជម្រះបាយឡុកបាយឡមួយ ដើម្បីបិទបាំងជនជាប់ចោទពីការទទួលខុសត្រូវឧក្រិដ្ឋកម្មអន្តរជាតិ

12. គោលការណ៍ជាមូលដ្ឋាន នៅពីក្រោយការលើកលែងទាំងនេះ គឺត្រូវអនុញ្ញាតឱ្យមានការចោទប្រកាន់ និងការជំនុំជម្រះលើកទីពីរចំពោះបុគ្គលមួយរូប ដែលបានប្រព្រឹត្តអំពើដូចគ្នា ឬស្រដៀងគ្នា និងឋិតក្រោមចរិតលក្ខណៈច្បាប់ដូចគ្នា ឬស្រដៀងគ្នានឹងកិច្ចដំណើរការនីតិវិធីលើកទីមួយ ដែលគេបានរៀបចំឡើង ដើម្បីជាសវាងពីទំនួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលនោះ ឬរៀបចំឡើងដើម្បីឱ្យជួបឧបសគ្គ ដោយសារភាពមិនសមស្របនៃនីតិវិធីទាំងស្រុងរបស់តុលាការ ឬការចោទប្រកាន់។

---

[២] ចូរមើលសំណុំរឿងAntonio. ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ. Oxford: Oxford University Press, 2003 (ទំព័រ ៣១៩-៣២១)។

[៣] *Ibid ទំព័រ ៣២១*

13. ក្នុងករណី ការជំនុំជម្រះនិងសាលក្រមរបស់តុលាការបដិវត្តប្រជាជនអាចបដិសេធ ឬ មានទំនាក់ទំនងជាមួយ យុត្តាធិការអ.វ.ត.ក ក្នុងការចោទប្រកាន់ និងជំនុំជម្រះភាគីបណ្តឹងឧទ្ធរណ៍ ការិយាល័យសហចៅក្រមស៊ើបអង្កេត ខកខានពុំបានពន្យល់ឱ្យបានគ្រប់គ្រាន់ អំពីករណីលើកលែង ដែលអាចអនុវត្តទៅបានចំពោះគោលការណ៍ជំនុំជម្រះពីរដងចំពោះបទល្មើសតែមួយ។ វាស្តែងឱ្យឃើញនូវភាពមិនច្បាស់លាស់ពីការអានប្រតិចារិតស្តីពីការជំនុំជម្រះ ឬសាលក្រមរបស់តុលាការបដិវត្តប្រជាជន ប្រសិនបើគេយកករណីលើកលែងណាមួយក្នុងចំណោមករណីលើកលែងទាំងនេះមកអនុវត្ត[៤]។ ដោយមិនគិតទៅដល់បញ្ហានៃការលើកលែងនៃដំណើរការកាត់ទោសរបស់តុលាការប្រជាជនបដិវត្តការិយាល័យសហចៅក្រមស៊ើបអង្កេតមិនអាចសន្និដ្ឋានដោយខ្លីថាឲ្យតែមានការលើកលែងដែលមានមួយឬច្រើនគឺអាចយកគោលការណ៍កាត់ទោសពីរដងមកអនុវត្តបាននោះទេ ព្រោះវាខ្វះភស្តុតាងបញ្ជាក់។ ដោយសារតែខ្លួនបានលើកឡើងនូវបញ្ហាពាក់ព័ន្ធនឹងគោលការណ៍[5]ការលើកលែងនេះឡើង ការិយាល័យសហចៅក្រមស៊ើបអង្កេតបានប្រកាន់ជំហរមួយគឺខ្លួនមួយដែលមិនពឹងផ្អែកលើសាលដីការបស់តុលាការបដិវត្តឡើយ។ ចំនុចនេះគឺបានន័យថា "ការវិភាគស៊ីជម្រៅ" របស់ការជំនុំជម្រះក្តីនៅតុលាការបដិវត្ត គឺគ្មានភាពច្បាស់លាស់ មិនអាចយកជាការបាន និងងាយពេក។

14. ការិយាល័យសហចៅក្រមស៊ើបអង្កេត មិនត្រូវលើកឡើងនូវសាលក្រមរបស់តុលាការប្រជាជនបដិវត្តមកធ្វើជាឧបសគ្គដល់កិច្ចដំណើរការនីតិវិធីរបស់ អវតក នោះទេ។ ការធ្វើដូច្នេះ គឺពិតជារារាំងដល់ការជំនុំជម្រះក្តីលើភាគីប្តឹងឧទ្ធរណ៍។ អង្គជំនុំជម្រះគួរតែពិចារណាទាំងទៅលើលក្ខណៈ និងបរិបទនៃការជំនុំជម្រះក្តីរបស់តុលាការប្រជាជនបដិវត្ត ក៏ដូចជាសាលដីការបស់តុលាការនេះ។ ខ្លួនមិនត្រូវបំភ្លេចចោលនូវចំណុចទាំងពីរនេះទាំងអស់តែម្តងនោះទេ។ ចំណុចសំខាន់មួយទៀតគឺថាគោលការណ៍នៃការកាត់ទោសពីរដងលើបទល្មើសតែមួយនេះ គឺវាមានពិតជាក់ស្តែងនៅក្នុងបរិបទនេះឯង។ ការជំនុំ

[៤] ចូរមើលជាទូទៅ: ប្រល័យពូជសាសន៍នៅកម្ពុជា - ឯកសារពីការជំនុំជម្រះប៉ុល ពត និងអៀងសារី Eds., Howard J. De Nike, John Quigley, Kenneth J. Robinson ជាមួយHelen Jarvis និងNereida Cross. Philadelphia: សាកលវិទ្យាល័យPennsylvania Press. ២000។

[៥] ដីកាសម្រេចសម្រេចឃុំខ្លួន កថាខណ្ឌ៨។

ជម្រះក្តី និងសាលដីការបស់តុលាការប្រជាជនបដិវត្តកាលពីឆ្នាំ១៩៧៩ គឺមិនអាចយកមក ធ្វើសំអាងគ្រប់គ្រាន់ដើម្បីជាប្រយោជន៍ដល់ អវតក នោះទេ ត្បិតអីម្ចាស់បណ្តឹងឧទ្ធរណ៍ គាត់បានទទួលការលើកលែងទោសរួចទៅហើយ។ ដូច្នេះបើទោះជាការនេះមិនដាក់កំហិត ទៅលើការសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតរបស់ អវតក ក៏ដោយ (សូមមើលសេចក្តីសម្រេច) ក៏វាពិតជាបានធ្វើមោឃភាពដល់អានុភាពនៃការជំនុំជម្រះក្តី សាលដីកា និងទោសទណ្ឌរបស់តុលាការបដិវត្តចំពោះម្ចាស់បណ្តឹងឧទ្ធរណ៍។

**B. ការិយាល័យសហចៅក្រមស៊ើបអង្កេត មានសិទ្ធិឃុំខ្លួនភាគីបណ្តឹងឧទ្ធរណ៍បណ្តោះអាសន្ន ទោះបីមានការលើកលែងទោសហើយក៏ដោយ**

15. ការអនុវត្តន៍ថ្មីនេះទាំងនៅក្នុងបរិយាកាសជាតិ និងអន្តរជាតិមានការគាំទ្រ ដល់ការហាម ឃាតការលើកលែងចំពោះឧក្រិដ្ឋកម្មអន្តរជាតិ។ ឧទាហរណ៍ ដូចជា តុលាការសិទ្ធិ មនុស្សអាមេរិកបានកំណត់ថា ផ្តល់ការលើកលែងទោសដល់ អ្នករំលោភច្បាប់សិទ្ធិ មនុស្សធម៌ ដូចជា ការធ្វើទារុណកម្ម សំលាប់មនុស្សក្រៅច្បាប់ និងបង្ខំឱ្យលាក់ខ្លួន(ដែល បង្កើតជាមូលដ្ឋាននៃការចោទប្រកាន់មួយចំនួនប្រឆាំងនឹងភាគីបណ្តឹងឧទ្ធរណ៍)គឺផ្ទុយនឹង សិទ្ធិរួចពីការចោទប្រកាន់ មានចែងក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងពុំមានអនុភាពផ្នែក ច្បាប់ទាល់តែសោះ[៦]។ កិច្ចព្រមព្រៀងសន្តិភាពរវាងរដ្ឋាភិបាលសេរ៉ាលេអូន និងរណសិរ្ស បដិវត្តសេរ៉ាលេអូន បដិសេធថា "ការលើកលែងទោស...មិនត្រូវអនុវត្តចំពោះបទឧក្រិដ្ឋ អន្តរជាតិឡើយ"[៧]។ មាត្រា១០នៃលក្ខន្តិកៈរបស់តុលាការពិសេសសេរ៉ាលេអូនចែងបន្ថែម ទៀតថា ផ្តល់ការលើកលែងទោសចំពោះបទឧក្រិដ្ឋទាំងឡាយ ដែលធ្លាក់ក្រោមយុត្តាធិការ របស់តុលាការ "ពុំត្រូវជាឧបសគ្គដល់ការជំនុំជម្រះឡើយ"។

16. មាត្រា៤០នៃច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ពុំទៅណាឆ្ងាយពីនេះទេ។ មាត្រានេះរួមបញ្ចូល នូវការប្តេជ្ញាពីរាជរដ្ឋាភិបាលកម្ពុជា មិនស្នើសុំការលើកលែងទោស ហើយទុកឱ្យអ.វ.ត.ក

[៦] សំណុំរឿង*Barrios Altos* (*Chumbipuma Aguirre និងអ្នកផ្សេងទៀត* ទល់នឹង*Peru*) អង្គការសិទ្ធិមនុស្សអាមេរិក សាលក្រមថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០១។

[៧] ឯកសារUN. S/1999/777

សម្រេចពីវិសាលភាពនៃការលើកលែងទោសពីមុនមក។ ទោះយ៉ាងណា យើងយល់ព្រមជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត[៨]ដែលថា មាត្រា៤០ត្រូវបានរួមបញ្ចូលយ៉ាងច្បាស់ ដើម្បីអាចឱ្យគេចោទប្រកាន់ និងជំនុំជម្រះទោសភាគីបណ្តឹងឧទ្ធរណ៍ ដែលទទួលបានការលើកលែងទោសនោះបាន។ វាបង្ហាញនូវជំហរក្នុងច្បាប់ទំនាមទំលាប់អន្តរជាតិ នៅពេលវិធានទូទៅហាមឃាត់ចំពោះបទឧក្រិដ្ឋឃោរឃៅជាអន្តរជាតិក្លាយជាបទដ្ឋានតម្រូវជាអន្តរជាតិ នោះវិធានទាំងនេះអាចបកស្រាយថាជាការជំទាស់ទៅនឹងកាតព្វកិច្ចដែលមិនត្រូវលប់ចោលដោយសារតែអំណាចប្រតិបត្តិ នៅពេលដែលបទឧក្រិដ្ឋទាំងនេះកើតឡើង ដូចដែលវិធានបានចែង[៩]។ ដោយសារតែបទឧក្រិដ្ឋអន្តរជាតិបង្កើតជាការវាយប្រហារទៅគុណតម្លៃសាកល គ្មានរដ្ឋាភិបាលរបស់រដ្ឋណាមួយគួរទាមទារសិទ្ធិរបស់ខ្លួនដើម្បីសម្រេចលប់ចោលនូវបទឧក្រិដ្ឋទាំងនោះ ឬទុកដោយនូវផលវិបាកផ្លូវច្បាប់របស់ខ្លួននោះឡើយ។

**C. បទដ្ឋាននៃការពិនិត្យឡើងវិញរបស់តុលាការ តម្រូវឱ្យបដិសេធចោលដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយការដោះលែងឱ្យនៅក្រៅឃុំពុំងាយស្រួលក្នុងការបំពេញបានឡើយ**

*a) ការិយាល័យសហចៅក្រមស៊ើបអង្កេតមានឆន្ទានុសិទ្ធិចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ឬដោះលែងឱ្យនៅក្រៅឃុំ និងពិនិត្យសេចក្តីសម្រេចរបស់ខ្លួនឡើងវិញ ក្នុងករណីចាំបាច់*

17. វិធាន៦៣-៦៥នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក ដែលទាក់ទងនឹងការដោះលែងបណ្តោះអាសន្ន ឬការឃុំខ្លួនបណ្តោះអាសន្ន មិនបានកំណត់យកវិធានសេរីភាព និងការឃុំខ្លួនធ្វើជាការលើកលែងសម្រាប់ជនជាប់ចោទដែលកំពុងរង់ចាំការជំនុំជម្រះក្តី។ ទោះយ៉ាងណា ការិយាល័យសហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នលុះត្រាខ្លួន យល់ឃើញថាជាវិធានការចាំបាច់មួយ។ ទោះបីជនជាប់ចោទមួយរូប

---

[៨] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន កថាខណ្ឌ១១។

[៩] Cassese, Antonio. ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ Oxford: Oxford University Press 2003 (ទំព័រ៣១៦)។ ចូរមើលផងដែរ: *Furundzija (បណ្តឹងផ្លូវការទៅប្រធានព្រះរាជអាជ្ញា)* ICTY អង្គបុរេជំនុំជម្រះII សេចក្តីសម្រេចថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៩៨ (សំណុំរឿងលេខ. IT-95-17/I-T កថាខណ្ឌ១៥៥)។

ត្រូវជាប់ឃុំក៏ដោយ ក៏ការិយាល័យសហចៅក្រមស៊ើបអង្កេតចេញដីកាសម្រេចដោះលែងឱ្យនៅក្រៅឃុំ នៅពេលណាក៏បានដែរ ឱ្យតែខ្លួនយល់ឃើញថា វាសមស្រប។ ជាធម្មតា *"ត្រូវតែផ្តោតការយកចិត្តទុកដាក់លើស្ថានភាពពិសេសនៃសំណុំរឿងនិមួយៗ ដោយមិនគិតថាលទ្ធផលជាយថាហេតុជាវិធាន ឬការលើកលែង"*[១០]

18. ជាវិធានទូទៅមួយ "ការសម្រេចដោះលែងជនជាប់ចោទគួរផ្អែកលើការធ្វើវិភាគមួយថាតើកត្តាទាំងឡាយនៃផលប្រយោជន៍សាធារណៈ ត្រូវលាតត្រដាងឡើងតាមរយៈការចោទប្រកាន់ឬយ៉ាងណា ចាំបាច់ត្រូវធានាដល់ការគោរពសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសេរីភាព"[១១] ម្យ៉ាងវិញទៀត នៅពេលកំណត់ថាតើត្រូវចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នឬអត់ ការដោះលែងឬការដាក់ឱ្យនៅថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ វាស្រេចតែទៅលើការិយាល័យសហចៅក្រមស៊ើបអង្កេត ជាអ្នកអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួន និងថ្លឹងថ្លែងរវាងតម្រូវការផលប្រយោជន៍សាធារណៈ និងសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានសេរីភាព។ អង្គជំនុំជម្រះនេះ ច្រានចោលសេចក្តីសម្រេចអំពីការប្តឹងឧទ្ធរណ៍បានលុះត្រាតែ (a)សំអាងលើការបកស្រាយមិនត្រឹមត្រូវមួយអំពីច្បាប់សំរាប់គ្រប់គ្រង (b)ផ្អែកលើការសន្និដ្ឋានអំពីអង្គហេតុមិនត្រឹមត្រូវ ឬ(c)មិនយុត្តិធម៌ ឬមិនសមហេតុផលរំលោភដល់ឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត[១២]

19. ការសម្រេចចេញដីកាឃុំខ្លួនបណ្តោះអាសន្ន ឬដោះលែងណាមួយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតគឺការសម្រេចប្រកបដោយឆន្ទានុសិទ្ធិសុទ្ធសាធ។ នោះគឺជាកិច្ចការសំខាន់។ អង្គជំនុំជម្រះឧទ្ធរណ៍នៅក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិកូនកាត់ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀតបានបញ្ជាក់ថា បទដ្ឋានត្រួតពិនិត្យការស្នើសុំប្តឹងឧទ្ធរណ៍

---

[១០] *ព្រះរាជអាជ្ញា ទល់នឹង Sesay* SCSL-04-15-PT-069 សេចក្តីសម្រេចស្តីអំពីការស្នើសុំដោះលែងបណ្តោះអាសន្ន កថាខណ្ឌ៣៩។ ចូរមើលផងដែរ *ព្រះរាជអាជ្ញា ទល់នឹង Miodrag Jokic និងព្រះរាជអាជ្ញា ទល់នឹង Rahim Ademi* IT-01-42-PT ដីកាសម្រេចលើការស្នើសុំដោះលែងបណ្តោះអាសន្ន អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២។

[១១] *ព្រះរាជអាជ្ញា ទល់នឹង Sesay* SCSL-04-15-PT-069 សេចក្តីសម្រេចស្តីអំពីការស្នើសុំដោះលែងបណ្តោះអាសន្ន កថាខណ្ឌ៣៩។

[១២] ចូរមើល*Slobodan Milosovic* ទល់នឹង*ព្រះរាជអាជ្ញា* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់នៃសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើការតែងតាំងមេធាវីការពារក្តី ICTY លេខសំណុំរឿង. IT-02054-AR7.3.7. ថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ២០០៤ កថាខណ្ឌ១០។

បន្ទាន់លក្ខណៈខ្ពស់ ពោលគឺ៖ គេមិនបានជ្រៀតជ្រែកដល់ឆន្ទានុសិទ្ធិនៃអង្គជំនុំជម្រះបណ្តឹងលើកទីមួយ លើកលែងតែក្នុងករណីពិសេស។ ដោយសារតែអង្គជំនុំជម្រះសាលាឧទ្ធរណ៍របស់ ICTY សង្កេតឃើញក្នុងករណីរបស់ *Milosevic* ថាសេចក្តីសម្រេចមួយត្រូវតែ "គ្មានភាពសមហេតុផលខ្លាំង រហូតអាចបង្ហាញឲ្យឃើញថាអង្គជំនុំជម្រះសាលាដំបូងខកខានមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យបានត្រឹមត្រូវតាមផ្លូវតុលាការ"[13]។ អង្គជំនុំជម្រះឧទ្ធរណ៍ របស់ SCSL បានអនុម័តយកបទដ្ឋានដូចគ្នា សំរាប់ការត្រួតពិនិត្យការសម្រេចដោះលែងរបស់តុលាការ។ ក្នុងសំណុំរឿងរបស់*Fofana* អង្គជំនុំជម្រះបានសម្រេចថា *"នៅពេលណាអង្គចៅក្រម ឬអង្គជំនុំជម្រះសាលាដំបូងបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការអនុញ្ញាត ឬបដិសេធការដោះលែង អង្គជំនុំជម្រះឧទ្ធរណ៍នឹងមិនជំនួសឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យអង្គចៅក្រម ឬអង្គជំនុំជម្រះសាលាដំបូងនោះទេ"*[១៤]។

20. អង្គជំនុំជម្រះនោះបានបន្ថែមថា ការសម្រេចបដិសេធដោះលែងឱ្យនៅក្រៅឃុំទុកជាមោឃៈទៅបាន លុះត្រាតែ *"ការ សម្រេចនោះផ្ទុយនឹងភាពសមហេតុផល និងគ្មានភស្តុតាងត្រឹមត្រូវ"*[១៥]។

21. គោលការណ៍នាំផ្លូវទាំងនេះអាចយកមកអនុវត្តបានសំរាប់រឿងក្តីបច្ចុប្បន្ន។

22. សេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ទំនងជាមិនអាចបំពេញបាននូវចំនុចចាប់ផ្តើមក្នុងកម្រិតខ្ពស់នៃភាពមិនសមហេតុផល។ អង្គជំនុំជម្រះឧទ្ធរណ៍ទាំងនៅICTY ទាំងនៅICTR និងSCSLបានបញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះឧទ្ធរណ៍អាចពិនិត្យអង្គហេតុដែលសម្រេចដោយអង្គជំនុំជម្រះសាលាដំបូងបាន លុះត្រាសេចក្តីសម្រេចលើ

---

[១៣] ទោះបីការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមែនជាអង្គជំនុំជម្រះមួយនៃអ.វ.ត.កក៏ដោយ ការសម្រេចដែលខ្លួនបានធ្វើឡើងទាក់ទងនឹងការឃុំខ្លួនភាគីបណ្តឹងឧទ្ធរណ៍គឺជាការសម្រេចមួយមានលក្ខណៈស្រដៀងគ្នាទៅនឹងការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង នៅតុលាការអន្តរជាតិមួយ។ សំណុំរឿងលេខ. IT-02-54-AR73.7, *ព្រះរាជអាជ្ញា ទល់នឹង Slobodan Milosevic* សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់នៃសេចក្តីសម្រេច របស់អង្គជំនុំជម្រះសាលាដំបូង លើការតែងតាំងមេធាវីការពារក្តី ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០០៤ នៅកថាខណ្ឌ១០។

[១៤] *ព្រះរាជអាជ្ញា ទល់នឹង Samuel Hinga Norman, Moinina Fofana និង Allieu Kondewa (SCSL-04-14-T)* Fofana- "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធការដោះលែង" ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ នៅកថាខណ្ឌ ២០។

[១៥] *Ibid កថាខណ្ឌ២០។*

អង្គហេតុនោះមានកំហុសឆ្គងទាំងស្រុង ការជម្រះអង្គហេតុមិនមានសេចក្ដីសន្និដ្ឋានដូចគ្នាបានទេ។ ដូចអង្គជំនុំជម្រះឧទ្ធរណ៍នៅICTRបានកត់សំគាល់ក្នុងសំណុំរឿងក្ដីរបស់ Semanaz ថា *"អំពីប្ដឹងឧទ្ធរណ៍ ភាគីមួយមិនអាចលើកអំណះអំណាងដដែល ដែលមិនបានទទួលជោគជ័យក្នុងសវនាការ ដោយសង្ឃឹមថា អង្គជំនុំជម្រះឧទ្ធរណ៍នឹងពិចារណាសារជាថ្មី។ កិច្ចដំណើរការប្ដឹងឧទ្ធរណ៍គឺមិនមែនជាកិច្ចដំណើរជំនុំជម្រះសារជាថ្មីទេ ហើយអង្គជំនុំជម្រះអង្គជំនុំជម្រះឧទ្ធរណ៍មិនមែនជាអង្គជំនុំជម្រះទីពីរលើអង្គហេតុនោះទេ។"*[១៦]

23. អាចនិយាយបានដូចគ្នាថា បណ្ដឹងឧទ្ធរណ៍ត្រូវធ្វើឡើងនៅដំណាក់កាលអង្គបុរេជំនុំជម្រះទៅអង្គជំនុំជម្រះ(Honourable Chamber)។ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានបង្ហាញច្បាស់នូវកត្តាជាច្រើនដែលត្រូវយកទៅពិចារណាទៅក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្លួន ក្នុងកថាខណ្ឌ១៥-២១នៃដីកាសម្រេចឃុំខ្លួន។ ទោះបីអង្គជំនុំជម្រះ(Honourable Chamber)នេះ មិនឯកភាពជាមួយការសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ការមិនឯកភាពនេះមិនអាចជាមូលហេតុក្នុងទុកសេចក្ដីសម្រេចនោះជាមោឃៈបានទេ។ ករណីយុត្តិសាស្ត្រលើអង្គហេតុស្នើថា អង្គជំនុំជម្រះ(Honourable Chamber) មិនគួរពិចារណាលើអំណះអំណាងនោះសារជាថ្មី ឬដាក់ជំនួសនូវឆន្ទានុសិទ្ធិរបស់ខ្លួនសំរាប់ការិយាល័យសហចៅក្រមស៊ើបអង្កេត ក្នុងការចេញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន។ ប្រសិនបើអង្គបុរេជំនុំជម្រះទុកសេចក្ដីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត(OCIJ)ជាមោឃៈ យើងសូមជំរុញឱ្យអង្គជំនុំជម្រះពន្យល់ពីភាពខុសគ្នារវាងបទដ្ឋានត្រួតពិនិត្យរបស់ខ្លួន និងបទដ្ឋានត្រួតពិនិត្យនៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិកូនកាត់ដទៃទៀត ការអនុវត្តន៍និងករណីយុត្តិសាស្ត្រ ដែលជាប្រភពច្បាប់ដែលគួរអនុវត្តតាមសំរាប់អង្គជំនុំជម្រះ(Honourable Chamber)។

---

[១៦] *ព្រះរាជអាជ្ញា ទល់នឹងSemanza* ICTR-97-20-A សាលក្រមថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ៨។ ចូរមើលផងដែរនូវ *ព្រះរាជអាជ្ញា ទល់នឹងAlex Tamba Brima, Brima Bazzy Kamara, និងSantigie Bobor Kanu* សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់មេធាវីBrima-Kamaraប្រឆាំងនឹងអង្គជំនុំជម្រះសាលាដំបូងII សេចក្ដីសម្រេចភាគីច្រើនសុំតែងតាំងKevin Metzger និងWilbert Harrisជាថ្មីជាមេធាវីសំរាប់លោកAlex Bamba BrimaនិងBrima Bazzy Kamara កថាខណ្ឌ១១២។

24. ក្នុងករណី ដែលអង្គជំនុំជម្រះ(Honourable Chamber)សម្រេចថា ចំនុចចាប់ផ្តើមសំរាប់ត្រួតពិនិត្យសេចក្តីសម្រេចOCIJត្រូវបានបំពេញនោះ កត្តាសំខាន់មួយផ្សេងទៀតត្រូវលើកយកទៅពិចារណា ពោលគឺ៖ OCIJអាចពិនិត្យឡើងវិញនូវដីកាសម្រេចឃុំខ្លួនតាមការស្នើសុំរបស់ខ្លួន នៅពេលថ្ងៃក្រោយ[១៧]។

25. អង្គជំនុំជម្រះ(Honourable Chamber)គួរតែកត់សំគាល់អំពីនីតិវិធីនៃការត្រួតពិនិត្យទៀតពេលមួយ បង្កើតឡើងដោយវិធានផ្ទៃក្នុង ដែលគេអាចកំណត់ដាច់ដោយឡែកពីវិធានសំរាប់គ្រប់គ្រងការឃុំខ្លួនបណ្តោះអាសន្ន និងការដោះលែងឱ្យនៅក្រៅឃុំ ក្នុងតុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត[១៨]។ មិនដូចវិធាននានារបស់ICTY ICTR និងSCSL វិធាន៦៤ និង៦៥នៃវិធានផ្ទៃក្នុងចែងថា ដីកាសម្រេចឃុំខ្លួនមុនការជំនុំជម្រះមានលក្ខណៈបណ្តោះអាសន្នតែប៉ុណ្ណោះ ហើយផ្តល់ឆន្ទានុសិទ្ធិបន្ថែមឱ្យOCIJក្នុងការពិនិត្យឡើងវិញនូវដីការបស់ខ្លួន ហើយស្នើរកការដោះលែងភាគីបណ្តឹងឧទ្ធរណ៍ នៅដំណាក់កាលក្រោយមកទៀត។ ជាជំរើស ភាគីបណ្តឹងឧទ្ធរណ៍អាចដាក់ពាក្យស្នើសុំការដោះលែង ទៅ OCIJ នៅពេលណាមួយក៏បាន ក្នុងអំឡុងពេលនៃការឃុំខ្លួនបណ្តោះអាសន្ន ភាគីបណ្តឹងឧទ្ធរណ៍អាចប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់OCIJបាន ឬដាក់ពាក្យស្នើសុំបន្ថែមក្នុងចន្លោះពេលបីខែ ស្នើរកការពិចារណាលើដីការបស់OCIJ ប្រសិនបើគាត់អាចបង្ហាញថា មានការប្រែប្រួលក្នុងស្ថានភាពរបស់គាត់។

26. ការពិតដែលថា អ.វ.ត.កមាននីតិវិធីពិនិត្យតាមដានទៀតទាត់មួយដើម្បីធានាថា ការឃុំខ្លួនរយៈពេលយូរណាមួយចាំបាច់ត្រូវលើកយកទៅពិនិត្យនៅពេលពិចារណា អំពីភាពខ្លាំងនៃអំណះអំណាងរបស់ភាគីបណ្តឹងឧទ្ធរណ៍ ក្នុងការគាំទ្រដល់ការដោះលែងបន្ទាន់របស់គាត់[១៩]។ ជាពិសេស ត្រូវចងចាំថា ដីកាសម្រេចឃុំខ្លួនមិនដកហូតការស្វែងរកដំណោះ

---

[១៧] វិធាន៦៤ វិធានផ្ទៃក្នុង។

[១៨] ចូរមើល ជាពិសេស វិធាន៦៤ និង៦៥នៃវិធាននៃនីតិវិធីនិងភស្តុតាងសំរាប់ICTY(វិធាននៃនីតិវិធីនិងភស្តុតាង IT/32/Rev, ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០០៧) និងICTR (វិធាននៃនីតិវិធីនិងភស្តុតាង ដូចបានកែប្រែនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ២០០៦) និងវិធាន៦៤នៃតុលាការពិសេសសំរាប់ប្រទេសសេរ៉ាលេអូន។

[១៩] យោងតាមសេចក្តីសម្រេចក្នុងរឿងក្តី*Ademi* រយៈពេលនៃការឃុំខ្លួនមុនការជំនុំជម្រះ គឺកាន់តែមានពាក់ព័ន្ធក្នុងបរិបទតុលាការអន្តរជាតិ “ដោយហេតុថា ក្នុងប្រព័ន្ធតុលាការអន្តរជាតិ ជាទូទៅមិនដូចនៅក្នុងប្រព័ន្ធយុត្តាធិការជាតិទេ គ្មាននីតិ

ស្រាយបន្ថែមណាមួយរបស់ភាគីបណ្តឹងឧទ្ធរណ៍ នៅដំណាក់កាលក្រោយមកទៀតនៃការឃុំខ្លួនគាត់ទេ ប្រសិនបើការឃុំខ្លួនបណ្តោះអាសន្នរបស់គាត់ពិតជាបង្ហាញច្បាស់ថាមិនចាំបាច់ ពោលគឺ ក្នុងករណីនោះ ភាគីបណ្តឹងឧទ្ធរណ៍មានសិទ្ធិពេញលេញក្នុងការស្នើរកការដោះលែងនៅក្រៅឃុំ។

ខ) ការខកខានមិនបានបញ្ចូលអង្គហេតុទៅក្នុងសម្អាងហេតុនៃសេចក្តីសម្រេចរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការសម្រេចឲ្យឃុំខ្លួន គឺមិនមែនជាកំហុសឆ្គងដែលអាចប្តឹងឧទ្ធរណ៍បានឡើយ។

27. ទោះបីពិចារណាទៅលើអង្គច្បាប់ ដើម្បីធ្វើសេចក្តីសម្រេចរបស់ខ្លួននៃដីកាឃុំខ្លួនមាន៧ទំព័រក៏ដោយ ក៏យើងខ្ញុំកត់សំគាល់ឃើញថា OCIJបានផ្តល់ការពិភាក្សានៅមានកម្រិតលើមូលដ្ឋានជាក់ស្តែង ដែលគាំទ្រដល់ការធ្វើសេចក្តីសម្រេចនោះ ការធ្វើសេចក្តីសម្រេចនោះមានពុំលើសពី៤កថាខណ្ឌទេ។

28. យើងខ្ញុំយល់ឃើញថា សេចក្តីសម្រេចប្រកដោយឆន្ទានុសិទ្ធិមួយ ដូចជា ដីកាសម្រេចឃុំខ្លួនមិនត្រូវមានដោយហេតុពេញលេញទេ ឱ្យតែបានកំណត់នូវអត្តសញ្ញាណនៃគ្រោះថ្នាក់ជាក់លាក់[២០] ប៉ុន្តែOCIJបានធ្វើការបកស្រាយតិចតួចណាស់អំពីអង្គហេតុ ដែលនៅពីក្រោយគ្រោះថ្នាក់ជាក់លាក់ទាំងនេះ។ ឧទាហរណ៍ OCIJពុំបានទាញសំអាងភស្តុតាងណាមកអះអាងបញ្ជាក់ថា *"ក្នុងបរិបទប្រកបដោយភាពងាយផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន"* ភាគីបណ្តឹងឧទ្ធរណ៍ដែលជាប់ចោទពីបទប្រព្រឹត្តឧក្រិដ្ឋកម្មទាំងឡាយគឺមានសភាពអាក្រក់ខ្លាំងណាស់ ដែលការដោះលែងរូបគាត់នេះអាចនាំឱ្យមានរឿង *"តវ៉ាមិនពេញចិត្តអាចនាំទៅរកអំពើហិង្សាបាន"* នៅក្នុងចំណោមប្រជាជនដែលអាច *"ធ្វើឱ្យ*

---

វិធីផ្លូវការផ្តល់សំរាប់ការត្រួតពិនិត្យទៀតទាត់នូវភាពចាំបាច់បន្តឃុំខ្លួនមុនការជំនុំជម្រះ។ ហេតុដូច្នេះ ប្រសិនបើក្នុងករណីពិសេសមួយ ការឃុំខ្លួនត្រូវធ្វើបន្ត វាអាចថា...*<u>កត្តានេះចាំបាច់ត្រូវផ្តល់ទម្ងន់បន្ថែមទៀត</u>* ក្នុងការពិចារណាថាតើជនជាប់ចោទនោះគួរត្រូវដោះលែងជាបណ្តោះអាសន្នឬយ៉ាងណា"។[មានបញ្ជាក់បន្ថែម]សំណុំរឿងលេខ. IT-01-46-PT (ICTY) *ព្រះរាជអាជ្ញា ទល់នឹងRahim Ademi* 'ដីកាសម្រេចលើការស្នើសុំដោះលែងបណ្តោះអាសន្ន" ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០២ កថាខណ្ឌ២៦។ ការពិចារណាស្មើភាព ការពិភាក្សាមានភាពពិតប្រាកដក្នុងរឿងក្តីនេះ។

[២០] ចូរមើល *ព្រះរាជអាជ្ញា ទល់នឹង Jadranko Prlic, Bruno Stojic, Slobodan Praljak, Milivoj Petrovic, Valentin Coric, និង Berislav Pusij,* "ដីកាសម្រេចឃុំខ្លួនJadranko Prlic បណ្តោះអាសន្ន" ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤, IT-01-46-PT។

*គ្រោះថ្នាក់សុវត្ថិភាពពិតប្រាកដ"* នៃភាគីបណ្ដឹងឧទ្ធរណ៍[២១]។ មេធាវីការពារក្ដីមានភាពត្រឹមត្រូវក្នុងការចង្អុលបង្ហាញថា OCIJពុំបានលើកយកផ្នែកណាមួយនៃភស្តុតាងមកចង្អុលបង្ហាញដល់ការអះអាងទាំងនេះទេ។ នេះជាការធ្វើឱ្យច្រឡូលច្របល់។ វាមិនមែនជាលើកទីមួយទេដែលOCIJបានអះអាងបែបនេះ ពោលគឺមានការអះអាងស្រដៀងគ្នានេះលេចឡើងក្នុងដីកាសម្រេចឃុំខ្លួនរបស់ខ្លួន ទាក់ទងនឹងជនត្រូវចោទផ្សេងទៀត។ ជាមួយគ្នានេះដែរ OCIJខកខានពុំបានវាយតម្លៃអំពីអង្គហេតុ ដែលគាំទ្រដល់ការអះអាងទាំងនេះ និងប្រតិកម្មឆ្លើយតបរបស់សាធារណៈជនខុសៗគ្នាទៅនឹងទស្សនៈនៃការដោះលែងជនត្រូវចោទម្នាក់ៗបណ្ដោះអាសន្នទេ។

29. ដូចភាគីបណ្ដឹងឧទ្ធរណ៍លើកឡើងថា ប៉ុន្តែមិនមែនមានន័យថា សង្គមកម្ពុជាគឺជា *"រូបភាពមួយនៃសន្តិភាព និងស្ថេរភាពទេ"*ហើយក៏មិនមែនមានន័យដែរថា ការលើកឡើងណាមួយដែលថា សង្គមកម្ពុជាអាចងាយផុយស្រួយ ដែលតម្រូវឱ្យឃុំខ្លួនភាគីបណ្ដឹងឧទ្ធរណ៍បណ្ដោះអាសន្ន ទើបហៅថា ជាភាពត្រឹមត្រូវ និងភាពអនាគតិនៃកិច្ចដំណើរការទាំងមូលរបស់អ.វ.ត.កនោះដែរ[២២]។ ការអំណះអំណាងលើកទីមួយគឺជាពិតជាត្រឹមត្រូវ ហើយការអះអាងលើកទីពីរមិនសមហេតុផលទេ។ មានភស្តុតាងជាច្រើន (ចូរមើលខាងក្រោម) ដូចដែលភាគីបណ្ដឹងឧទ្ធរណ៍ទទួលស្គាល់ថា កម្ពុជាដែលងើបចេញរបបខ្មែរក្រហមមួយ បាននាំទៅរកកុបកម្មមានរយៈពេលតិចជាង១០ឆ្នាំកន្លងទៅ កម្ពុជាពុំទទួលបាននូវសុខសន្តិភាពនយោបាយសង្គម (ឬសន្តិភាពផ្លូវចិត្ត)ទេ។ លើសពីនេះទៅទៀត ការតវ៉ាជាសាធារណៈដែលពួកគេគិតថា ច្បាប់នឹងមិនអាចមានទិសដៅត្រឹមត្រូវបានទេ ប្រសិនបើភាគីបណ្ដឹងឧទ្ធរណ៍ត្រូវបានដោះលែងបណ្ដោះអាសន្ន ហើយអាចរត់គេចខ្លួន ឬជ្រៀតជ្រែកដល់កិច្ចដំណើរការអ.វ.ត.ក ក្នុងរូបភាពណាមួយ ដែលជាកត្តាពាក់ព័ន្ធមួយ ដែលត្រូវពិនិត្យដើម្បីសម្រេចថាតើ ការឃុំខ្លួនបណ្ដោះអាសន្នគឺជាការចាំបាច់ ដើម្បីធានាការពារសណ្ដាប់ធ្នាប់សាធារណៈឬយ៉ាងណា។ ចេញពីបញ្ហានៃភាពត្រឹមត្រូវ (ក្នុងករណីមានការអនុញ្ញាត) ការឃុំខ្លួនបណ្ដោះអាសន្នអាចជាមធ្យោបាយមួយសមស្របដើម្បីធានាដល់ភាពត្រឹមត្រូវ។

---

[២១] ដីកាសម្រេចឃុំខ្លួន កថាខណ្ឌ១៦។

[២២] សារណានៃបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ៩ និង១៣។

00192157

E221/I/14

30. គេមិនអាចជឿបានទេចំពោះការអះអាងរបស់OCIJ ទាក់ទងទៅនឹងការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ ក្នុងករណីមានការដោះលែងភាគីបណ្តឹងឧទ្ធរណ៍បណ្តោះអាសន្ន ដូចដែលភាគីបណ្តឹងឧទ្ធរណ៍ហាក់ដូចបានលើកឡើងនោះ។ OCIJ ស្វែងរកការគាំទ្រពីការសិក្សាស្រាវជ្រាវ និងអង្កេតដ៏លើសលប់ ដែលធ្វើឡើងដោយអង្គការសង្គមស៊ីវិលជាតិ និងអន្តរជាតិ ឬអ្នកសិក្សាស្រាវជ្រាវទាំងឡាយទាក់ទងនឹងអារម្មណ៍របស់សាធារណៈជនអំពីការឃុំខ្លួនភាគីបណ្តឹងឧទ្ធរណ៍មុនការជំនុំជម្រះ និងការជំនុំជម្រះទាំងឡាយនៅចំពោះមុខ អ.វ.ត.កជាទូទៅ។ សមាជិកទាំងឡាយនៃសាធារណៈជនកម្ពុជាបានអញ្ជើញមកសំដែងនូវទស្សនៈរបស់ខ្លួនថា (a) ការជំនុំជម្រះគឺជាភាពចាំបាច់មួយសំរាប់ការជាសះស្បើយ និងការសម្រះសម្រួលឡើងវិញ (b)ពួកគាត់មានមន្ទិលអំពីកិច្ចដំណើរការដោយយុត្តិធម៌ ដោយហេតុថា រដ្ឋាភិបាលមាន "*សមាជិកអតីតខ្មែរក្រហមនៅក្នុងដៃ*" ហើយ(c)ពួកគាត់ត្រូវការការធានាបញ្ជាក់សារជាថ្មីថា ពួកគាត់មិនចាំបាច់ខ្លាច "*វប្បធម៌នៃនិទ្ទណ្ឌភាព*"កើតឡើងជាថ្មីនោះទេ។ សូម្បីតែពីមុនមកក៏ពួកគាត់មួយចំនួនបានចោទសួរនូវអ្វីដែលនឹងកើតឡើង ប្រសិនបើជនជាប់ឃុំ(Detainees)ទាំងនោះ "*មិនចូលរួមជាមួយតុលាការ*" ឬ "*បដិសេធរាល់ភស្តុតាងទាំងអស់*" និងថាតើអតីតមេដឹកនាំទាំងឡាយដែលបាន "*សម្រះសម្រួលជាមួយរដ្ឋាភិបាល*" នឹងញុះញ៉ង់ឱ្យមានជម្លោះស៊ីវិលម្តងទៀត ប្រសិនបើពួកអតីតមេដឹកនាំទាំងនោះត្រូវនាំខ្លួនទៅកាន់ការជំនុំជម្រះ[២៣]។ ការសិក្សាស្រាវជ្រាវបឋមៗផ្សេងទៀតចង្អុលបង្ហាញថា យុវជនកម្ពុជាភ័យខ្លាចថា ការជំនុំជម្រះនេះនឹងញុះញង់ឱ្យមានជម្លោះបន្ថែមទៀត ហើយពួកគេថា គួរបង្វែរមូលនិធិដែលបានមកនោះទៅជាតម្រូវការអភិវឌ្ឍន៍ប្រទេសវិញប្រសើរជាង[២៤]។

---

[២៣] ទស្សនៈរបស់អ្នកចូលរួមក្នុងវេទិកាសាធារណៈដើម្បីយុត្តិធម៌ និងការបង្រួបបង្រួមឡើងវិញ រៀបចំដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម ក្នុងខេត្តកំពង់ធំ (ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៧) ក្រុងកែប (ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៧) ចូរមើលរបាយការណ៍នៃផ្នែកវេទិកាសាធារណៈនៅ www.csdcambodia.org. ស្តីអំពី "វប្បធម៌នៃនិទ្ទណ្ឌភាព" ចូរមើល Craig Etcheson បន្ទាប់ពីវាលពិឃាត: មេរៀនពីប្រល័យពូជសាសន៍កម្ពុជា។ Westport: Praeger ២០០៥។

[២៤] Mohan Ramani, Vinita. ស្មារតីសង្គម និងសង្គមស៊ីវិល ក្រោយជម្លោះនៅកម្ពុជា។ សៀវភៅសរសេរដោយដៃមិនមានការបោះពុម្ព ៖ មូលនិធិអាហារូបករណ៍អាស៊ី ២០០៧-២០០៨ (ទំព័រ ២៥-២៧)។ អ្នកនិពន្ធក៏បានដឹកនាំការអង្កេតបឋមមួយផងដែរទៅលើយុវជនកម្ពុជាចំនួនជាង៧០នាក់ ហើយបានរកឃើញថា យុវជនកម្ពុជាជាច្រើនមានអារម្មណ៍ថាប្រព័ន្ធច្បាប់កម្ពុជារៀបចំឡើងជាសំខាន់ដើម្បីផ្គាប់ចិត្តអ្នកទាំងឡាយណា ដែលមានឥទ្ធិពលនយោបាយ និង/ឬទាក់ទងជា

31. OCIJ ខកខានមិនបានប្រើប្រាស់ប្រភពស្រដៀងគ្នានៃទស្សនៈសាធារណៈទាំងនេះ។ ទោះបីជាមានករណីយុត្តិសាស្ត្រនាំមុខគេស្នើឡើងថា ការលុបចោលអង្គហេតុក្នុងដីកាសម្រេចឃុំខ្លួនរបស់OCIJមិនមែនជាកំហុសឆ្គងនៃការអាចប្តឹងឧទ្ធរណ៍បាន (បានកំណត់ខាងលើ)។ ម៉្យាងវិញទៀត ហេតុផលរបស់OCIJប្រើសំរាប់ចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នក្នុងកថាខណ្ឌ ១៥ - ២១ នៃដីកាសម្រេចឃុំខ្លួនពុំមានហេតុផលសមស្រប ឬខ្វះការវិនិច្ឆ័យត្រឹមត្រូវ។

32. ក្នុងករណីនេះ យើងខ្ញុំសូមជំរុញឱ្យអង្គជំនុំជម្រះផ្តល់ការណែនាំឱ្យបានច្បាស់លាស់មួយក្នុងសេចក្តីសម្រេចរបស់ខ្លួនទៅOCIJ អំពីរបៀបបំពេញលក្ខខណ្ឌរបស់ខ្លួន ដើម្បីដាក់ចេញការសំអាងអង្គហេតុក្នុងការឃុំខ្លួន ក្នុងគ្រប់សំណុំរឿងនិមួយៗ យោងតាមវិធាន៦៣ (២)(ក) និង(៣)នៃវិធានផ្ទៃក្នុង។

*គ) ភាគីប្តឹងឧទ្ធរណ៍ទទួលបន្ទុកបញ្ជាក់ថាហេតុអ្វីដីកាសម្រេចឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលា ការត្រូវជំនួសដីកាបង្គាប់ឱ្យឃុំខ្លួនរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។*

៣២. បន្ទុកភស្តុតាងគឺនៅលើភាគីប្តឹងឧទ្ធរណ៍ដើម្បីបញ្ជាក់ប្រាប់អង្គបុរេជំនុំជម្រះថា ដីកាសម្រេចឱ្យស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការត្រូវជំនួសដីកាបង្គាប់ឱ្យឃុំខ្លួនរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត។[25]បើសិនជាត្រូវដោះលែង ភាគីប្តឹងឧទ្ធរណ៍បានលើកមូលហេតុជាច្រើនក្នុងការបង្ហាញថា គាត់នឹងមិនរត់គេចចេញពីការជំនុំជម្រះទេ។[26] គាត់ក៏ធ្វើការកត់សំគាល់នៅក្នុងសារណាឧទ្ធរណ៍ផងដែរថា

---

មួយរដ្ឋាភិបាល។ ចូរមើលផងដែរ Aafke Sanders។ The Evil Within- Genocide, Memory and Mythmaking in Cambodia។ Unpublished Masters dissertion។ Radboud University Nijmegen, Amsterdam ខែវិច្ឆិកា ឆ្នាំ២០០៦ (ទំព័រ ៥៥-៦៤)។

[25] ករណីលេខ IT-04-84-PT រដ្ឋអាជ្ញាទល់នឹងRamush Haradinaj, Idriz Balaj និង Lahi Brahimaj ក្តីសម្រេចស្តីអំពីញត្តិរបស់Ramush Haradinajសម្រាប់ការដោះលែងជាបណ្តោះអាសន្ន ថ្ងៃទី៦ ខែ មិថុនាឆ្នាំ២០០៥ ក្នុងកថាខណ្ឌ២១។

[26] សារណាឧទ្ធរណ៍ កថាខណ្ឌ៣៧-៣៩

បណ្តឹងប្រហាក់ប្រហែលគ្នារបស់ជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋសាហាវដូចបទឧក្រិដ្ឋដែលភាគីប្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់
ត្រូវបានអនុញ្ញាតដោយសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី។[27]

៣៣.
ការពិនិត្យករណីទាំងនេះឡើងវិញរបស់សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដែលភាគីប្តឹងឧទ្ធរណ៍បញ្ជាក់ប្រាប់ថា
មូលហេតុទាំងអស់ឬភាគច្រើនខាងក្រោមនេះត្រូវមាននៅក្នុងបណ្តឹងស្វែងរកការបញ្ចុះបញ្ចូលសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសុំឱ្យដោះលែងភាគីប្តឹងឧទ្ធរណ៍ជាបណ្តោះអាសន្នឬដោះលែងឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ:
(i)
ការប្រកាសជាសាធារណៈដោយជនត្រូវចោទចំពោះអនុភាពដែលគាត់នឹងមិនរឹងរូសចំពោះសាលាក្តីដែលជាប់ទាក់ទង ឬថា គាត់គោរពនីតិវិធីការតុលាការ
(ii)
សេចក្តីបញ្ជាក់ចរិយាមាយាទចំពោះភាពសុចរិតបុគ្គលរបស់ជនជាប់ចោទដែលរួមមានសេចក្តីប្រកាសពីរដ្ឋាភិបាលជាប់ពាក់ព័ន្ធ ឬពីការិយាល័យអង្គការសហប្រជាជាតិចំពោះអនុភាពនេះ
(iii) ការធានាអះអាងជាលាយលក្ខណ៍អក្សរដោយជនជាប់ចោទថា
គាត់នឹងអនុវត្តឱ្យបានពេញលេញតាមលក្ខខណ្ឌនៃការដោះលែងជាបណ្តោះអាសន្ន
និងមិនធ្វើការរំខានណាមួយដល់ជនរងគ្រោះ ឬសាក្សីមានសក្តានុភាព ឬក៏រំខានដល់រដ្ឋបាលតុលាការ
និង
(iv)
ការធានាអះអាងជាលាយលក្ខណ៍អក្សរពីអាជ្ញាធររដ្ឋាភិបាលជាប់ពាក់ព័ន្ធដែលពួកគេមាននយោបាយនិងសមត្ថភាពចាប់ខ្លួនជនជាប់ចោទ បើសិនជាគាត់ព្យាយាមរត់គេច។[28]

---

[27] សារណាឧទ្ធរណ៍ កថាខណ្ឌ៣៩

[28] សូមអាន ករណីលេខ IT-04-84-PT រដ្ឋអាជ្ញាទល់នឹងRamush Haradinaj, Idriz Balaj និង Lahi Brahimaj ក្តីសម្រេចស្តីអំពីញត្តិរបស់Ramush Haradinajសម្រាប់ការដោះលែងជាបណ្តោះអាសន្ន ថ្ងៃទី៦ ខែ មិថុនាឆ្នាំ២០០៥។

៣៤.
ឧបសគ្គបីដែលរារាំងដល់ការដោះលែងភាគីប្ដឹងឧទ្ធរណ៍ជាបណ្ដោះអាសន្នឬដោះលែងឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។

៣៥. ទីមួយ ដោយសារការិយាល័យសហចៅក្រមស៊ើបអង្កេតបានធ្វើការសង្កេតយ៉ាងត្រឹមត្រូវថា ភាគីប្ដឹងឧទ្ធរណ៍បានថ្លែងជាសាធារណៈលើសពីម្ដងថា គាត់នឹងប្រឆាំងនឹង អ. វ. ត. ក។[29] សេចក្ដីប្រកាសទាំងនេះធ្វើឱ្យអន្តរាយដល់ការធានាអះអាងយ៉ាងយឺតយ៉ាវរបស់ភាគីប្ដឹងឧទ្ធរណ៍ថា ឥឡូវគាត់នឹងសហការជាមួយនឹង អ. វ. ត. ក ដើម្បីរកឱ្យឃើញការពិត។

៣៦. ទីពីរ បើទោះជា ភាគីប្ដឹងឧទ្ធរណ៍(ឬមេធាវីរបស់គាត់) បានសំដែងកាយវិការនៃបំណងល្អ និងត្រៀមធានាអះអាងបញ្ជាក់អំពីការបង្ហាញខ្លួនក្នុងសាលាក្ដីក៏ដោយ ក៏ "ការធានាគឺគ្រាន់តែជាការធានាប៉ុណ្ណោះ បើសិនជាភាគីប្ដឹងឧទ្ធរណ៍អាចធានាបាន យ៉ាងហោចណាស់ធ្វើឱ្យតុលាការពេញចិត្តដែរ"។[30]

៣៧. មិនមានសិទ្ធិចេញដីកាសម្រេចឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការដោយខ្លួនឯងទេ ដោយមានន័យថា ជនជាប់ចោទមានសិទ្ធិទទួលបានការដោះលែងលុះត្រាតែអាជ្ញាធរជំនុំជម្រះក្ដីអាចបញ្ជាក់ការចោទប្រកាន់ជាពិសេសប្រឆាំងនឹងគាត់ វាជាសិទ្ធិស្នើសុំដីកាសម្រេចឱ្យនៅក្រៅឃុំ ចំពោះតុលាការដែលបើកចំហរឱ្យបញ្ចុះបញ្ចូលថាការឃុំឃាំងចុងចោទមុនការជំនុំជម្រះមិនចាំបាច់ការពារ

---

ករណីលេខ IT-04-74-PT រដ្ឋអាជ្ញាទល់នឹងJadrako Prlic, Bruno Stojic, Slobodan Praljak, Milivoj Petrovic, Valentin Coric និង Berislav Pusij " ដីកាដោះលែង Jadranko Prlic ជាបណ្ដោះអាសន្ន ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ២១ IT-01-46-PT និងរដ្ឋអាជ្ញាទល់នឹងRahim Ademi "ដីកាស្ដីអំពីញត្តិដោះលែងជាបណ្ដោះអាសន្ន"ថ្ងៃទី២០ ខែកុម្ភៈឆ្នាំ២០០២ កថាខណ្ឌ២៩-៣០

[29] ដីកាឃុំខ្លួន កថាខណ្ឌ១៨

[30] រដ្ឋអាជ្ញាទល់នឹង Fofana, SCLS-04-14-AR65 ធ្វើឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចបដិសេធមិនឱ្យនៅក្រៅឃុំស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ កថាខណ្ឌ៣៩។

ប្រសិទ្ធភាពការជំនុំជម្រះ ឬសម្រាប់ហេតុផលសាធារណៈណាផ្សេងទេ។[31] ពីព្រោះចៅក្រម David Hunt បានអង្កេតនៅក្នុងSainovic ថា "បញ្ហាកាន់តែធ្ងន់ធ្ងរ ឬផលវិបាកពីលទ្ធផលសេសកាន់តែធ្ងន់ធ្ងរនឹងមានការលំបាកកាន់តែខ្លាំងក្នុងការធ្វើឱ្យសាលាក្តីដែលជាប់ទាក់ទងយល់ព្រមថាអ្វីដែលពោលអះអាងនោះប្រហែលជាពិតច្រើនជាងមិនពិត។ នោះគ្រាន់តែជាសុភវិនិច្ឆ័យប៉ុណ្ណោះ"។ [32]បន្ទាប់មកអង្គជំនុំជម្រះត្រូវតែបញ្ជាក់ថាបើសិនជាមានចេញដីការសម្រេចឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ភាគីប្តឹងឧទ្ធរណ៍ (ក) មិនកៀបសង្កត់សាក្សី ឬជនរងគ្រោះ ឬមិនរំខានដល់នីតិវិធីតុលាការទេ (ខ) នៅរក្សាសេចក្តីសុខសាន និង (គ) បង្ហាញខ្លួននៅក្នុងការជំនុំជម្រះ និង (ឃ) មិនគេចចេញពីផ្លូវច្បាប់ដើម្បីចៀសវាងពីការអាចជាប់ពន្ធនាគារអស់មួយជីវិត។ នៅទីបញ្ចប់ អង្គជំនុំជម្រះនេះត្រូវតែសួរថាតើត្រូវមានបទបញ្ហាសាធារណៈឬទេ។ នៅក្នុងការធ្វើសេចក្តីសម្រេចនេះត្រូវតែទទួលយកយុត្តាធិការនៃភាពតឹងរ៉ឹងនិងភាពជាក់ស្តែងនៃបទឧក្រិដ្ឋដែលភាគីប្តឹងឧទ្ធរណ៍ត្រូវបានចោទប្រកាន់ក៏ដូចជាឥទ្ធិពលមានសក្តានុភាពដែលការដោះលែងភាគីប្តឹងឧទ្ធរណ៍ជាបណ្តោះអាសន្នត្រូវតែមានទំនុកចិត្តជាសាធារណៈថាកម្ពុជាគឺជានីតិរដ្ឋ។

៣៨. នៅក្នុងសេចក្តីសម្រេចទាក់ទងទៅនឹងការឃុំខ្លួនជាបណ្តោះអាសន្នចំពោះ កាំង ហ្កេកអ៊ាវ ឈ្មោះក្រៅ "ឌុច" អង្គជំនុំជម្រះនេះបានផ្អែកទៅលើការធ្វើអង្កេតរបស់អង្គការសង្គមស៊ីវិល ដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបង្ហាញថា សាក្សីមានសក្តានុពល "បារម្ភថា ជនត្រូវចោទរសាច់ញាតិរបស់ពួកគេអាចកៀបសង្កត់ពួកគេ ឬធ្វើការសងសឹក"។[33] ការបារម្ភដូចគ្នានេះ (បើសិនជាមិនត្រូវបានពង្រឹង) កើតមានក្នុងចំណោមសាក្សីមានសក្តានុពលឬសាក្សីដែលមានបំណងមករក និង

---

[31] សូមអាន រដ្ឋអាជ្ញាទល់នឹង Fofana, SCLS-04-14-AR65 ធ្វើឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចបដិសេធមិនឱ្យនៅក្រៅឃុំស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៥ កថាខណ្ឌ៣១- ៣២។

[32] រដ្ឋអាជ្ញាទល់នឹងNikola Sainovic &Dragoljub Ojdanic, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ជំទាស់នឹងយោបល់របស់ចៅក្រមDavid Hunt ស្តីអំពីការដោះលែងជាបណ្តោះអាសន្ន ថ្ងៃទី៣០ ខែតុលាឆ្នាំ២០០២ កថាខណ្ឌ២៩។

[33] អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចស្តីពីការធ្វើឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្នទៅលើរូបកាំង ហ្កេចអ៊ាវ ឈ្មោះក្រៅ "ឌុច" ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ៣៣ ៣៥។

ផ្តល់ភស្តុតាងនៅក្នុងការជំនុំជម្រះប្រឆាំងនឹងភាគីប្តឹងឧទ្ធរណ៍។ ទីបញ្ចប់ភាគីប្តឹងឧទ្ធរណ៍សប្បាយរីករាយនឹងបញ្ហាទំនាស់នយោបាយនិងហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។

៣៩. ជាជំហររបស់ខ្លួន អ. វ. ត. ក ត្រូវបង្កើតអង្គភាពគាំពារសាក្សីនិងកំពុងស្វែងរកជំនួយការសាក្សីដែលនឹងត្រូវបំពេញការងារ ផ្សេងៗ " ដោយរក្សាសុខុមាលភាពរបស់សាក្សី ជាពិសេសសាក្សីដែលងាយរងគ្រោះនិងស្ថិតក្រោមការគំរាមកំហែង និងធានាថា សាក្សីទាំងអស់មានភាពងាយស្រួលនិងត្រូវបានថែទាំអំឡុងពេលពួកគេស្នាក់នៅក្នុងទីក្រុងភ្នំពេញ នៅ អ. វ. ត. ក"។[34] ក្នុងកាលៈទេសៈនេះ មិនអាចនិយាយដោយមានទំនុកចិត្តថា យន្តការកមពុងអនុវត្តដើម្បីការពារសាក្សីមានសក្តានុពលបើសិនជាភាគីប្តឹងឧទ្ធរណ៍ត្រូវបានដោះលែងដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ។ លើសពីនេះទៀតការស្តាបប់ចម្លើយឯករាជ្យបង្ហាញថាសាក្សីមានសក្តានុពលដែលមានបំណងមកកាន់តុលាការ កំពុងរង់ចាំការណែនាំរបស់ អ. វ. ត. ក ចំពោះរឿងនេះនិងមិនធ្វើដូច្នេះទេល្គឹកណាតែពួកគេត្រូវបានផ្តល់ការធានាអះអាងឱ្យបានគ្រប់គ្រាន់ថាពួកគេនិងគ្រួសាររបស់ពួកគេនឹងមិនរងគ្រោះថ្នាក់ទេបើសិនជាពួកគេបានបង្ហាញព័ត៌មានសំខាន់ទាក់ទងទៅនឹងភាគីប្តឹងឧទ្ធរណ៍។[35]

៤០. ទីបញ្ចប់ សារណាឧទ្ធរណ៍មិនមានឬមិននិយាយអំពីការធានាណាមួយពីរាជរដ្ឋាភិបាលកម្ពុជាថាពួកគេមានមធ្យោបាយនិងសមត្ថភាពចាប់ខ្លួនជនជាប់ចោទ បើសិនជាគាត់ព្យាយាមរត់គេច។ រឿងនេះគឺជាការបំភ្លេចចោលយ៉ាងសំខាន់។ ជាការពិត "សហប្រតិបត្តិការរដ្ឋជាដៃគូសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីគឺជាកត្តាសម្រេច "នៅពីក្រោយការដោះលែងជនត្រូវចោទថ្មីៗនេះជាបណ្តោះអាសន្ន។[36]រឿងដដែលនេះមិនអាចនិយាយអំពីសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រ៉្វាន់

[34] http://www.eccc.gov.kh/english/job_opportunity.aspx$mode=viewArcive$doc_id=9

[35] បទសម្ភាសន៍ជាមួយស្ត្រីអ្នកឆ្លើយតបពីបាត់ដំបង។ បទសម្ភាសន៍ដោយខិម ចរិយា និង Vinita Mohan អំឡុងពេលការធ្វើដំណើររបស់អ្នកស្រុកបាត់ដំបងរៀបចំដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម នៅសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៧ ប្រវត្តិការណ៍មិនបោះពុម្ពផ្សាយរបស់អង្គភាពវេទិកាសាធារណៈរបស់CSD។

[36] Cryer, Robert, Hakan Friman, Darryl Robinson, Elizabeth Wilmhust។ <u>ការណែនាំចំពោះនីតិវិធីនិងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ</u>។ Cambridge: Cambridge University Press ឆ្នាំ២០០៧។ (ទំព័រ៣៧០)។

ដា ឬអំពីបរិបទកម្ពុជាថ្មីបើមានហេតុការថា អ. វ. ត. ក គឺជាសាលាក្តីកម្ពុជា/សហប្រជាជាតិអន្តរជាតិ។ គេរំពឹងថា ទោះណាជាដំណើរការប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជាខុសប្លែកពីដំណើរការប្រតិបត្តិការដែលទាក់ទងទៅនឹងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី/សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់រវ៉ាន់ដាដោយការធានាអះអាងមួយចំនួនតិចតួចណាស់ពីក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលដែលលើកឡើងថា ពួកគេមានសមត្ថភាពក្នុងការធ្វើឱ្យប្រាកដថា ភាគីប្តឹងឧទ្ធរណ៍នឹងមិនអាចរត់គេចពីប្រទេសបានទេ បើសិនជាគាត់ត្រូវបានដោះលែង។ គ្មានការធានាបែបនេះនៅពេលនេះទេ។ ផ្ទុយទៅវិញ មានការបារម្ភយ៉ាងខ្លាំងថា អាជ្ញាធរកម្ពុជា/ អ. វ. ត. ក មិនមានធនធានធានាបញ្ជាក់ថា ភាគីប្តឹងឧទ្ធរណ៍មិនរំខានដល់ដំណើរការតុលាការ អនុវត្តលក្ខខណ្ឌដោះលែងដែលបានស្នើសុំរបស់ភាគីប្តឹងឧទ្ធរណ៍ ឬមានអនុភាពទៅលើការចាប់ខ្លួនមកវិញ បើសិនជាគាត់ត្រូវបានដោះលែង។

៤១. ការពោលរបស់ភាគីប្តឹងឧទ្ធរណ៍ចំពោះឯកឧត្តមនាយករដ្ឋមន្ត្រី សម្តេចហ៊ុន សែន“កិច្ចប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីនាំសន្តិភាពនិងភាពសុខសានដល់ប្រទេសកម្ពុជា ” ជាមូលដ្ឋានសន្និដ្ឋានថា ភាគីប្តឹងឧទ្ធរណ៍នឹងរស់នៅដោយសុវត្ថិភាព ដោយមិនមានការឃុំខ្លួនជាបណ្តោះអាសន្ន គ្មានការរំខាន គិតតែផលប្រយោជន៍ផ្ទាល់ខ្លួន។ វាហាក់ដូចជាការព្រមានដោយលួចលាក់មួយចំពោះអង្គជំនុំជម្រះនេះមិនឱ្យដីកាឃុំខ្លួនបណ្តោះអាសន្ន។ យើងគិតថា សេចក្តីថ្លែងនេះមិនជម្រុញករណីរបស់ភាគីប្តឹងឧទ្ធរណ៍ទៅមុខទេ។ បើសិនជាមាន វានឹងបង្ហាញទំនាក់ទំនងដែលត្រូវបានរាយការណ៍របស់ភាគីប្តឹងឧទ្ធរណ៍ (និងបណ្តាក្រុមគ្រួសាររបស់គាត់) ទៅនឹងគណបក្សកាន់អំណាចដោយការតាមឃ្លាំមើលរបស់ជនកម្ពុជាមានហេតុផល អាចឱ្យភាគីប្តឹងឧទ្ធរណ៍ស្ថិតនៅលើច្បាប់ បើសិនជាតាមបំណងរបស់គាត់ផ្ទាល់ ឬយ៉ាងហោចណាស់ក្នុងស្ថានភាពរំខានដល់រដ្ឋបាលតុលាការដែរ។[37]

---

[37] Heder, Steven។ “ខ្មែរក្រហមរបួតផុតពីការដាក់ទោសម្តងទៀតហើយ”។ កាសែត ភ្នំពេញប៉ុស្ត៍ លេខ៧/១៣ ថ្ងៃទី៣-១៦ ខែកក្កដា ឆ្នាំ១៩៩៨។ ដកស្រង់សក្ខីភាពពិនិត្យហើយរបស់លោក
សាស្ត្រាចារ្យHederនៅចំពោះមុខអនុគណៈកម្មាធិការទំនាក់ទំនងបរទេសព្រឹទ្ធសភាអាមេរិកផ្នែកអាស៊ីបូព៌ានិងប៉ាស៊ីហ្វិច។ សក្ខីភាពបង្ហាញអំពីសម្ព័ន្ធភាពនយោបាយនៃថ្ងៃនិថបញ្ហាអាចកើតមាន ដែលអាចបង្កើតឡើងសម្រាប់សាលាក្តី។

៤២.ទន្ទឹមនឹងភាគីប្តឹងឧទ្ធរណ៍បានដកស្រង់របាយការណ៍ពីកម្មវិធីអភិវឌ្ឍន៍សហប្រជាតិនិងធនាគារពិភពលោកដែលលើកឡើងថា "សន្តិភាពពេញលេញសម្រេចបាននៅក្នុងឆ្នាំ១៩៩៩ប៉ុណ្ណោះ" មិនដល់ ១០ឆ្នាំកន្លងមកនេះទេ ក៏ដូចជាការរិះគន់ថ្មីៗនេះអំពីការបរាជ័យប្រព័ន្ធច្បាប់ដើម្បីរកយុត្តិធម៌។ កម្ពុជានៅតែស្ថិតក្នុងស្ថានភាពអន់តាមការវាយតម្លៃជាអន្តរជាតិនៅក្នុងរបាយការណ៍សិទ្ធិមនុស្ស និងជាពិសេសនៅក្នុងបញ្ហាទាក់ទងទៅនឹងច្បាប់នឹងបទបញ្ញា។ អំពើពុករលួយនៅក្នុងកងកំលាំងប៉ូលិស និងតុលាការ និងអំពើហិង្សាជាពិសេសប្រឆាំងនឹងគណបក្សនយោបាយប្រឆាំង គឺដោយអន្លើ។[38] នៅក្នុងរបាយការណ៍របស់ខ្លួនស្តីអំពីកម្ពុជាសម្រាប់ឆ្នាំ២០០៧អង្គការលើកលែងទោសអន្តរជាតិលើកឡើងថា "ការកែទម្រង់ដែលរង់ចាំជាយូរមកហើយ ដែលរួមបញ្ចូលច្បាប់គ្រប់គ្រងតុលាការនិងប្រព័ន្ធព្រហ្មទណ្ឌមិនបានកើតមានទេ" និងថា "ច្បាប់ប្រឆាំងនឹងអំពើពុករលួយដែលត្រូវបានចាត់ថាជាអាទិភាពកំពូលនៅក្នុងសេចក្តីថ្លែងការណ៍របស់កិច្ចប្រជុំប្រចាំឆ្នាំរបស់ប្រទេសផ្តល់ជំនួយកាលពីខែមីនាមិនត្រូវបានអនុម័តទេ។[39] ការសម្លាប់លោកជា វិជ្ជា សកម្មជនសហជីព និងការឃុំខ្លួនគួរឱ្យសង្ស័យ ប៊ន សំណាង និងសុខ សំអឿន នៅក្នុងករណីនេះ តាមការរាយការណ៍អាចទុកថាជាមន្ត្រីប៉ូលិសជាន់ខ្ពស់ដែលនៅរួចខ្លួននៅឡើយ និងមានទំនាក់ទំនងជិតស្និទ្ធជាមួយវរជនគណបក្សកាន់អំណាច។[40] ដូច្នេះមានកំលាំងបន្តិចបន្តួចឬគ្មានកំលាំងនៅក្នុងសេចក្តីសំអាងរបស់ភាគីប្តឹងឧទ្ធរណ៍ដែលការប្រឹងប្រែងម

---

[38] "សហរដ្ឋអាមេរិកៈ មេប៉ូលិសអសោចល្ហោះកម្ពុជានៅអាមេរិកដើម្បីពិភាក្សាអំពីការប្រឆាំងភេរវកម្មនៅការិយាល័យសហព័ន្ធស៊ើបអង្កេតFBI"។ អង្គការតាមឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៧។ http://hrw.org/english/docs/2007/04/16/usint15717.htm ក៏សូមអានៈ "កម្ពុជា ១០ឆ្នាំក្រោយគ្មានយុត្តិធម៌ចំពោះការវាយប្រហារដោយគ្រាប់បែកដៃទៅលើក្រុមប្រឆាំងទេ"។ អង្គការតាមឃ្លាំមើលសិទ្ធិមនុស្ស ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៧។ <http://hrw.org/english/docs/2007/03/28/cambod15587.htm> ក៏សូមអានរបាយការណ៍ពេញលេញខាងក្រោម ឆ្នាំ២០០៦ <http://hrw.org/englishwr2k7/docs/2007/01/11/cambod14866.htm>

[39] សូមអាន បណ្តាញទំនាក់ទំនងដូចតទៅសម្រាប់របាយការណ៍ពេញលេញ http://thereport.amnesty.org/eng/Regions/Asia-Pacific/Cambodia

[40] "កម្ពុជាៈ ស្ថានភាពសិទ្ធិមនុស្សឆ្នាំ២០០៦"។ គណៈកម្មការសិទ្ធិមនុស្សអាស៊ី សូមអាន http://material.ahrchk.net/hrrport/2006/Cambodia2006.pdf ក៏សូមអាន វង្ស សុខេង "ក្មួយលោកហ៊ុន សេន នៅមិនទាន
ចាប់ខ្លួន ចំនួនស្លាប់កើនឡើង" កាសែតភ្នំពេញប៉ុស្តិ៍ លេខ១២/២៣ ថ្ងៃទី៧-២០ ខែវិច្ឆិកា ឆ្នាំ២០០៣។

ហិមាត្រូវបានធ្វើឡើងដើម្បី "នាំសន្តិភាពនិងសេចក្តីសុខសាន្តដល់ប្រទេសកម្ពុជា" ទទួលបានជោគជ័យគ្រប់គ្រាន់។[41]

ឃ) ការជំនុំជម្រះទោសភាគីប្តឹងឧទ្ធរណ៍គឺមហិមា

៤៣. លើសពីនេះទៀតសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីមានការយកចិត្តទុកដាក់អំពីរយៈពេលជនជាប់ចោទនឹងត្រូវរង់ចាំការប្រឈមមុខនឹងការជំនុំជម្រះក្តីនៅពេលបញ្ជាឱ្យដោះលែងជាបណ្តោះអាសន្ន ។ ឧទាហរណ៍ នៅក្នុងករណី Ademi អង្គជំនុំជម្រះសាលាដំបូងបានពិចារណាអំពីអង្គហេតុថា វាហាក់ដូចជាថា ការជំនុំជម្រះជនជាប់ចោទនឹងមិនចាប់ផ្តើមក្នុងពេលឆាប់ៗទេ។[42] រយៈពេលដែលភាគីប្តឹងឧទ្ធរណ៍ប្រហែលជាស្ថិតនៅក្នុងពន្ធនាគារបន្តទៀត ត្រូវយកមកពិចារណា នៅពេលកំណត់ថាតើដោះលែងគាត់ជាបណ្តោះអាសន្នដែរឬទេក៏ដូចជាត្រូវការអ្វីដើម្បីធានាថាភាគីប្តឹងឧទ្ធរណ៍នៅតែស្ថិតក្នុងសភាពមានយុត្តិធម៌។ ការឃុំខ្លួនបន្តប្រាំមួយខែ ដែលជាការពិនិត្យឡើងវិញបន្តទៀតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតធ្វើឱ្យរយៈពេលឃុំខ្លួនភាគីប្តឹងឧទ្ធរណ៍ជាបណ្តោះអាសន្នអាចខុសពីច្បាប់ករណីសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីដែលគាត់ពឹងផ្អែក ។

**v. សេចក្តីសន្និដ្ឋាន**

៤៤. យើងសង្ឃឹមថា ការពិនិត្យស្ទង់របស់យើងអំពីយុត្តិសាស្ត្រជាប់ទាក់ទងនិងការអនុវត្តរបស់លាក្តីឧក្រិដ្ឋកម្មអន្តរជាតិផ្សេងៗជួយដល់អង្គជំនុំជម្រះក្នុងការធ្វើសេចក្តីសម្រេចបើសិនជាការិយាល័យសហចៅក្រមស៊ើបអង្កេតត្រូវបញ្ជាឱ្យឃុំខ្លួនភាគីប្តឹងឧទ្ធរណ៍ជាបណ្តោះអាសន្ន។ ករណីទាំងនេះផ្តល់វការសន្និដ្ឋានថា ម៉្យាងតុល្យភាពត្រូវតែមានរវាងផលប្រយោជន៍សាធារណៈ និងម៉្យាងទៀតគម្រូវ

[41] មនោសញ្ចេតនាជាបន្តនៃកំហឹងឬការស្អប់និងកិច្ចប្រឹងប្រែងឆ្ពោះទៅរកការផ្សះផ្សា សូមអាន Craig Etchon "ហួសពីសាលាក្តីខ្មែរក្រហម"។ វិចារណកថា កាសែតភ្នំពេញប៉ុស្តិ៍ លេខ១២/២២ ថ្ងៃទី២៤ខែតុលា-ថ្ងៃទី៦ខែវិច្ឆិកាឆ្នាំ២០០៣។ ជាថែមទៀត ការចេញផ្សាយរបស់កាសែតភ្នំពេញប៉ុស្តិ៍មានចំណងជើងព័ត៌មានស្តីអំពីការសម្លាប់នាដការីនិងអ្នកកាសែតគាំទ្រគណបក្សហ៊្វុនស៊ិនប៉ិច សន្និដ្ឋានថា សន្តិភាពនិងស្ថេរភាពមិនមានជាក់ស្តែងភ្លាមៗទេពិតជាយឺតយ៉ាវដូចឆ្នាំ២០០៣។

[42] ករណីលេខ IT-01-46-PT (សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី) រដ្ឋអាជ្ញាទល់នឹងRahim Ademi "ដីកាស្តីអំពីញត្តិដោះលែងជាបណ្តោះអាសន្ន"ថ្ងៃទី២០ ខែកុម្ភៈឆ្នាំ២០០២ កថាខណ្ឌ៣៩។

C22/I/14.

ការធានាដល់ការគោរពសិទ្ធិសេរីភាពរបស់ភាគីប្តឹងឧទ្ធរណ៍។ ទីបំផុត សម្រាប់អង្គបុរេជំនុំជម្រះក្នុងការសម្រេចថាតើសេចក្តីសម្រេចជាឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតដែលលំអៀងទៅខាងអ្នកចាស់នោះ មិនមានហេតុផលជាក់ស្តែងនៅក្នុងកាលៈទេសៈ។ ដើម្បីធ្វើដូច្នេះ យើងសង្ឃឹមថាអង្គជំនុំជម្រះនេះនឹងផ្តល់ការណែនាំថាតើការិយាល័យសហចៅក្រមស៊ើបអង្កេតអាចដោះស្រាយឱ្យបានទូលំទូលាយអំពីមូលដ្ឋានពិតប្រាកដអំពីសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្នដើម្បីជៀសវាងការធ្វើឧទ្ធរណ៍ដែលមិនចាំបាច់។ យើងគិតថា ឆន្ទានុសិទ្ធិនេះមិនត្រូវបានរារាំងដោយគោលការណ៍នៃហានិភ័យស្ទួនចំពោះមុខអង្គបុរេជំនុំជម្រះ (ដែលមិនអនុវត្តនៅទីនេះ) ឬការលើកលែងទោសជាមុន (ដែលត្រូវបានអធិប្បាយត្រឹមត្រូវ) មិនមែនជារបាំងចំពោះការចោទប្រកាន់ឬការជំនុំជម្រះទោសរបស់ អ. វ. ត. ក ទេ។

(បានចុះហត្ថលេខា)

MAHDEV MOHAN

MOHAN

(បានចុះហត្ថលេខា)

VINITA RAMANI

ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨

Original EN: 00164285-00164303